+855 (0)17 774 864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

សា-សាបាសាក់ SA SA BASSAC

រស់មួយថ្ងៃគិតមួយថ្ងៃ គឺជាការពិពណ៌ម្នាក់ឯងដោយ Nguyen Thi Thanh Mai ដែលជាសិល្បករនៅខេត្ត Hue ប្រទេសវៀតណាម។ ការពិពណ៌នេះ ទាញចេញពីការស្រាវជ្រាវដែលសិល្បករបានធ្វើឡើងក្នុងរយៈពេលមួយឆ្នាំនៅក្នុងសហគមន៍នេសាទខ្នាតតូចជាច្រើននៅក្នុងខេត្តសៀមរាប និងខេត្តពោធិសាត់ នៃប្រទេសកម្ពុជា និងក្នុងខេត្តឡុងអាន នៃប្រទេសវៀតណាម។ បុរស ស្ត្រី និងកុមារ នៅក្នុងសហគមន៍ទាំងនេះ គឺជាជនជាតិវៀតណាមពីកំណើត ឬពីដូនតារបស់ពួកគេ ប៉ុន្តែពួកគេភាគច្រើនបានរស់នៅក្នុងប្រទេសកម្ពុជាជាច្រើនឆ្នាំឬច្រើនជំនាន់មកហើយ។ ទោះបីជាបែបនេះក្តីក៏ពួកគេភាគច្រើនមិនមានអត្តសញ្ញាណផ្លូវការមកពីប្រទេសណាមួយនោះទេ ដែលជាហេតុធ្វើឲ្យពួកគេមានការលំបាកជាហូរហែ។

ចំណងជើងពិពណ៌នេះ គឺជាឃ្លាមួយដែលសិល្បករខ្ចីពីអ្នកភូមិយកមកប្រើ។ នៅក្នុងការបង្ហាញរបស់សិល្បករ Nguyen លើកឡើងថា ការប្រើប្រាស់ឃ្លានេះជាញឹកញាប់របស់អ្នកភូមិ "ជាការគូររូបភាពនៃអនាគតរបស់ពួកគេ"។ ប៉ុន្តែ ដូចមានឃើញនៅក្នុងពិពណ៌ អតីតកាល និងអនាគតកាលបានផុសឡើងម្តងហើយម្តងទៀត ដូចជាមិនអាចបញ្ឈប់បានឡើយ។ អ្នកភូមិបាននិយាយជាចំហរអំពីការចងចាំរបស់ពួកគេ ដោយរាប់បញ្ចូលទាំងបទពិសោធន៍អំពីសង្គ្រាម និងជម្លោះ ប៉ុន្តែមិនបានរំលឹកអំពីក្តីស្រមៃរបស់ពួកគេឡើយ។

រស់មួយថ្ងៃគិតមួយថ្ងៃ បង្ហាញនូវកាលៈទេសៈមួយសំណុំដែលមានលក្ខណៈជាក់ច្បាស់ខ្លាំងអំពីករណីរបស់ជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា ប៉ុន្តែក៏មានការជាប់ទាក់ទងទូលាយ ដោយភប់ប្រសព្វជាមួយនឹងសំណួរជាសាកលមួយចំនួនអំពីភាពជាពលរដ្ឋនិងការធ្វើចំណាកស្រុក។

ពិពណ៌នេះ មានស្នាដៃជាប់ទាក់ទងគ្នាចំនួនបួន។ អត្តសញ្ញាណប័ណ្ណ (២០១៤) ជាការតម្លើងតាមបែបចូលរួម ដោយរួមមានឯកសារសម្គាល់ខ្លួន "មិនផ្លូវការ" ចំនួន ៣៤៨ ដោយបានផ្តិតនៅលើកំទេចកំណាត់ដែលអ្នកភូមិឲ្យទៅសិល្បករ។ ស្រមោល (២០១៤) ជាស៊េរីមួយនៃរូបថតឌីជីថលផាត់ពណ៌ដោយដៃ ដែលរូបមនុស្សត្រូវបានផាត់ឲ្យខ្មៅ កុំឲ្យឃើញអត្តសញ្ញាណរបស់បុគ្គលដើម្បីជាការការពារ និងការព្រលយបង្ហាញអំពីភាពមិនមិនប្រាកដប្រជាដែលមានជារួមក្នុងគំនិតរបស់សហគមន៍។ ស៊េរីមួយទៀតនៃការផ្តិតជារូបថត ការធ្វើដំណើរ (២០១៤) រួមមានការប្រើរូប collages ឌីជីថល ដែលមានរូបក្បាលអ្នកភូមិច្រើនផ្សេងគ្នា បត់ចូលក្នុងខ្លួនមនុស្សចម្លែកម្នាក់ ថតនៅក្នុងស្ទូឌីយោថតរូបមួយដែលគេតុបតែងឲ្យមើលទៅដូចជាដីដ៏សែនឆ្ងាយ។ ស៊េរីចុងក្រោយ រស់មួយថ្ងៃគិតមួយថ្ងៃ (២០១៤-២០១៥) គឺជាចំណងជើងវីដេអូមួយ ដែលមានពីរផ្នែក ដោយផ្អែកតាមការសម្ភាសន៍ដ៏វែងជាច្រើនជាមួយអ្នកភូមិ។

បន្ទាប់ពីការចាប់ផ្តើមនៅ ស ស បាសាក់, *រស់មួយថ្ងៃគិតមួយថ្ងៃ* នឹងធ្វើដំណើរទៅសារមន្ទីរវិចិត្រសិល្បៈ Sao La o Chi Minh ប្រទេសវៀតណាម។

*Day by Day* is a solo exhibition by Nguyen Thi Thanh Mai, an artist based in Hue, Vietnam. The exhibition draws on one year of extensive research by the artist in several small fishing communities in Siem Reap and Pursat, Cambodia as well as in Long An, Vietnam. The men, women and children in these communities are Vietnamese by birth or by ancestry, but many of them have lived in Cambodia for years or even for generations. Despite this, many of them do not have formal identification from either country, resulting in ongoing difficulties.

The title of the exhibition is a phrase the artist borrowed from the villagers. In her artist's statement, Nguyen suggests that the villagers' frequent use of this phrase "drew the picture of their future." Yet, as seen in Nguyen's exhibition, pasts and futures repeatedly emerge, as if irrepressible. Villagers speak openly of their memories, including experiences of war and conflict, but never of their dreams.

*Day by Day* presents a set of circumstances that are highly specific to the case of Vietnamese in Cambodia, yet also of broader relevance, intersecting with universal questions of citizenship and migration.

The exhibition consists of four interrelated serial works. *ID Card* (2014) is a participatory installation consisting of 348 "unofficial" identity documents printed on scraps of clothing donated to the artist by the villagers. *Shadow* (2014) is a series of hand-colored digital photographs in which the human figures have been blacked out, at once protectively obscuring individuals' identities and hinting at the community's shared uncertainty. Another series of photographic prints, *Travels* (2014), consists of digital collages in which a portrait of the head of various villagers is inserted onto the body of an unknown stranger, posing in a photo studio decorated to appear like a faraway land. Finally, *Day by Day* (2014-15) is the title of a video, in two parts, based in extended interviews with villagers.

**About the artist**

Nguyen Thi Thanh Mai (born 1983, Hanoi) is an artist based in Hue, Vietnam. Select exhibitions include *Swimming in Sand; Growing Rice Under an Umbrella* (Anita Archer Fine Art, Melbourne, Australia, 2014); *Unexpected* (Chiang Mai University Museum, 2014); 2013 *Asian Report* (Artspace A Gallery, Cheongju, South Korea, 2013); and *Riverscapes IN FLUX* (Goethe Institut, Vietnam, Thailand, Myanmar, Philippines, Indonesia, 2012). Residencies include Kunstlerhaus Bethanien, in Berlin, Germany (2015-2016), Sa Sa Art Projects, Phnom Penh (2014); HIVE Studio, Cheongju, South Korea (2013); New Space Arts Foundation, Hue, Vietnam (2013) and Sàn Art, Ho Chi Minh City, Vietnam (2012). Nguyen is a recipient of awards and grants from the Pollock-Krasner Foundation (2014-15) and the Cultural Development and Exchange Fund (2014 and 2012). In 2015 she is a finalist for the Sovereign Asian Art Prize, Hong Kong. The artist holds a Bachelor of Fine Arts from Hue College of the Arts, Vietnam (2006) and a Master of Visual Arts from Mahasarakham University, Thailand (2012).

**About the curator**

*Day by Day* is guest curated by Roger Nelson, an independent curator based in Phnom Penh and a PhD candidate at the University of Melbourne researching contemporary and modern Cambodian art and culture. www.rogernelson.net

After its debut at SA SA BASSAC, *Day by Day* will travel to Sao La, Ho Chi Minh Fine Arts Museum, Vietnam.

# រស់មួយថ្ងៃគិតមួយថ្ងៃ

ដោយង្វៀន ធីថាញ់ម៉ាយ

រៀបចំដោយ រ៉ជឺ នែលសិន

# DAY BY DAY

by Nguyen Thi Thanh Mai

curated by Roger Nelson

31 January – 08 March  2015




Nguyen Thi Thanh Mai, *ID Card*, 2014

អំពីសិល្បករ

Nguyen Thi Thanh Mai (កើតក្នុងឆ្នាំ១៩៨៣ នៅក្រុងហាណូយ) គឺជាសិល្បករមានមូលដ្ឋាននៅខេត្ត Hue ប្រទេសវៀតណាម។ ការពិពណ៌មួយចំនួនមានដូចជា *ហែលក្នុងខ្សាច់, ដាំស្រូវក្រោមឆ័ត្រ* (Anita Archer Fine Art, Melbourne, Australia, 2014), *មិនបានរំពឹងទុក* (សារមន្ទីរសាកលវិទ្យាល័យឈៀងម៉ៃ, ២០១៤); *របាយការណ៍អាស៊ី* ២០១៣ (Artspace A Gallery, Cheongju, ប្រទេសកូរ៉េខាងត្បូង, ២០១៣); និង *Riverscapes IN FLUX* (Goethe Institut, ប្រទេសវៀតណាម ប្រទេសថៃ ប្រទេសមីយ៉ាន់ម៉ា ប្រទេសហ្វីលីពីន ប្រទេសឥណ្ឌូណេស៊ី, ២០១២)។ ការទៅធ្វើការតាមប្រទេសរួមមាន Kunstlerhaus Bethanien, នៅប៊ែរឡាំង ប្រទេសអាឡឺម៉ង់ (២០១៥-២០១៦), គម្រោងសិល្បៈ ស ស នៅភ្នំពេញ (២០១៤), New Space Arts Foundation, ខេត្ត Hue, ប្រទេសវៀតណាម (២០១៣)។ Nguyen ជាអ្នកទទួលបានរង្វាន់និងប្រាក់ឧបត្ថម្ភមួយចំនួនពី Pollock-Krasner Foundation (2014-15) និង មូលនិធិអភិវឌ្ឍន៍និងផ្លាស់ប្តូរវប្បធម៌ (២០១៤ និង ២០១២)។ ក្នុងឆ្នាំ២០១៥ នាងជាបេក្ខជនចុងក្រោយម្នាក់សម្រាប់រង្វាន់ Sovereign Asian Art Prize នៅក្រុងហុងកុង។ សិល្បកររូបនេះ ទទួលបានបរិញ្ញាប័ត្រវិចិត្រសិល្បៈពីមហាវិទ្យាល័យសិល្បៈ Hue នៅប្រទេសវៀតណាម (២០០៦) និងបានសញ្ញាប័ត្រអនុបណ្ឌិតផ្នែក Visual Arts ពីសាកលវិទ្យាល័យមហាសារ៉ាខាម នៅប្រទេសថៃ (២០១២)។

អំពីអ្នករៀបចំ

*រស់មួយថ្ងៃគិតមួយថ្ងៃ* រៀបចំដោយ Roger Nelson ដែលជាអ្នករៀបចំឯករាជ្យម្នាក់ដែលមានមូលដ្ឋាននៅក្រុងភ្នំពេញ និងជាបេក្ខជនបណ្ឌិតនៅសាកលវិទ្យាល័យ Melbourne ដែលកំពុងធ្វើការស្រាវជ្រាវទៅលើសិល្បៈនិងវប្បធម៌សហសម័យនិងទំនើបនៅកម្ពុជា។

www.rogernelson.net